# អង្គជំនុំជម្រះសេចក្តីប្រឆាំង ឌុច ដំណើរការបន្ត

*ដោយ ឡូរ៉ា ម៉ាកដូណាល់*

*ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ខែន សុខស្រីនិត*

**ឆាក**

ក្រោយពីការធ្វើដំណើរតាមដងវិថីរួមគ្នាជាមួយនឹងរថយន្តតាក់ស៊ី រ៉ឺម៉ក រថយន្តតាក់ស៊ីមួយផ្សេងទៀតមក ខ្ញុំក៏បានមកដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដែលមានទីតាំងស្ថិតនៅជាយក្រុងភ្នំពេញទាន់ពេលវេលាសម្រាប់ដំណើរការបន្តអង្គជំនុំជម្រះក្តីរបស់ ឌុច ។ បន្ទាប់ពីត្រូវបានពិនិត្យរក អាហារ ភេសជ្ជៈ គ្រឿងអេឡិចត្រូនិច និងអាវុធចំនួនពីរលើកមក ខ្ញុំក៏បានចូលទៅដល់បន្ទប់តាមដានដំណើរការនីតិវិធីដែលត្រូវបានខាន់ដាច់ដោយឡែកដោយផ្ទាំងកញ្ចក់ ដែលទិដ្ឋភាពនេះបានធ្វើឲ្យខ្ញុំនឹកដល់ពេលដែលខ្ញុំបានទៅតាមដានការប្រកួតកីឡាវាយកូនហ្គោលលើទឹកកក និងការទស្សនាអាងចិញ្ចឹមត្រី ។ អ្នកតាមដានដំណើរការរបស់តុលាការមានចំនួនប្រមាណ៧៥នាក់ ដែលពាក់កណ្តាលជាប្រជាជនកម្ពុជា ។ ត្រឹមតែអាយុ២៨ឆ្នាំ ខ្ញុំមើលទៅគឺស្ថិតនៅក្នុងចំណោមអ្នកតាមដានដែលមានអាយុចាស់ជាងគេបង្អស់ ។ មានមនុស្សមួយក្រុមធំដែលមើលទៅទំនងជាក្រុមសិស្សវិទ្យាល័យ ហើយមានប្រជាជនកម្ពុជា និងជនជាតិបរទេសប្រមាណ៤៥នាក់ បានអង្គុយជាក្រុមៗដោយមានកាន់សៀវភៅកត់ត្រា ដែលអ្នកទាំងនោះមកធ្វើការតាមដានដំណើរការរបស់តុលាការជំនួសមុខឲ្យអង្គការរបស់គេ ។ ខ្ញុំបានអង្គុយនៅក្បែរភ្ញៀវទេសចរណ៍ពីរនាក់ ដែលមានកាន់សៀវភៅទេសចរណ៍នៅក្នុងដៃ ហើយក្រោយពីពេលឈប់សម្រាកសម្រាប់អាហារថ្ងៃត្រង់មក ភ្ញៀវទាំងពីរនាក់នេះមិនបានវិលត្រឡប់មកតាមដានដំណើរការនីតិវិធីវិញឡើយ ។

អ្វីៗគ្រប់យ៉ាងបានរៀបចំរួចជាស្រេច ។ អ្នកតាមដានបានផ្តល់ឲ្យនូវឯកសារដែលរៀបចំរួចជាស្រេចទាក់ទិននឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមទាំងព័ត៌មានពីអ្នកប្រតិបត្តិនីតិវិធីសំខាន់ៗនៅក្នុងអង្គជំនុំជម្រះសេចក្តីរបស់ ឌុច ។ ដំណើរការនីតិវិធីបានផ្សាយតាមរយៈប្រព័ន្ធបំពងសម្លេងជាភាសាខ្មែរ ប៉ុន្តែអ្នកតាមដានក៏អាចស្តាប់ពីដំណើរការនីតិវិធីជាភាសាបារាំង និងអង់គ្លេស ដោយប្រដាប់ស្តាប់

សម្លេងផ្ទាល់ខ្លួនដែលមានចែកជូននៅច្រកចូលបន្ទប់សវនាការ ។ ទូរទស្សន៍កញ្ចក់ស្ដើងត្រូវបានដាក់បំពាក់ នៅក្នុងកន្លែងតាមដានដែលអមដោយម៉ាស៊ីនត្រជាក់ ដើម្បីបង្ហាញរូបភាព អ្នកនិយាយ និងឯកសារគាំទ្រដែលអ្នកប្រតិបត្តិនីតិវិធីបានលើកឡើងឲ្យកាន់តែជិត និងច្បាស់ ។ ក្នុងអំឡុងពេលសម្រាក អ្នកតាមដានដំណើរការរបស់តុលាការអាចពិសារទឹកត្រជាក់ ប្រើប្រាស់ប្រព័ន្ធ អ៊ិនធឺណែត និងអង្គុយសម្រាកនៅហាងលក់អាហារបាន ។ ក្រៅពីការរៀបចំឯកសារទុករួចជាស្រេចការរៀបចំជាភាពងាយស្រួលទាំងអស់នេះបានធ្វើឲ្យដំណើរការតាមដានអង្គជំនុំជម្រះសេចក្ដីរបស់ ឌុច មានភាពរលូន ។

នៅផ្នែកម្ខាងទៀតនៃកញ្ចក់ អ្វីៗគ្រប់យ៉ាងមើលទៅមានលក្ខណៈតាមផ្លូវការ ។ ភាគីទាំងអស់បានសួរពាក់ទាក់គ្នាទៅវិញទៅមក ខណៈពេលដែលកំពុងតែរង់ចាំការមកដល់របស់ចៅក្រម ។ ស្នូរកន្ទឹងរូឡ៍ អ្នកតាមដានទាំងអស់ក្រោកឈរ ។ ចៅក្រមបានអញ្ជើញចូលក្នុងអង្គសវនាការ ។ គួរឲ្យកត់សម្គាល់ចៅក្រម ក្រឡាបញ្ជី និងមេធាវី ទាំងអស់ពាក់អាវវែងពណ៌ក្រហម ស្វាយ និងខ្មៅខុសៗគ្នា ។ សាក្សីបីរូប ព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់អង្គុយនៅមួយផ្នែក ហាក់បីដូចជាចាំបន្ទាចមេធាវីការពារក្ដី និង ឌុច ដែលអង្គុយនៅទល់មុខនោះ ។ ចៅក្រមអង្គុយបែរមុខចំទស្សនិកជន ប៉ុន្តែចៅក្រមមើលទៅដូចជាមិនយកចិត្តទុកដាក់ចំពោះអ្វីដែលនៅផ្នែកខាងក្រៅផ្ទាំងកញ្ចក់នោះទេ ។ ឌុច បានមើលមកកាន់ទស្សនិកជន ។ អង្គជំនុំជម្រះសេចក្ដីចាប់ផ្ដើមដំណើរការបន្ត ។

## ខ្លឹមសារ
## ការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១

ក្រោយពីការយកចិត្តទុកដាក់បញ្ហានីតិវិធីតូចមួយក្នុងការទទួលស្គាល់លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ប្រាតាណា ជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមពាមក លោកប្រធានចៅក្រម និល ណុន បានផ្ទេរភារកិច្ចទៅឲ្យលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីសួរសំណួរ ឌុច ពីការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ ។ មុននឹងឈប់សម្រាក ដោយសារមានការរំពឹងទុកនូវអង្គជំនុំជម្រះសេចក្ដីដែលមានដំណើរការទៅមុខឲ្យលឿន ចៅក្រមទាំងអស់បានព្រមព្រៀងឲ្យក្រឡាបញ្ជីជាតិរបស់ អ.វ.ត.ក អានកថាខណ្ឌស្ដីពីសេចក្ដីថ្លែងការណ៍ទាក់ទិននឹងប្រធានបទដែលទទួលស្គាល់រួមមាន យោបល់ដែលបញ្ជាក់ដោយជនត្រូវចោទ ឌុច និងដើម្បីឲ្យ ឌុច បានបន្ថែមយោបល់និងសេចក្ដីបញ្ជាក់បន្ថែមទៀត ។ មានភាពច្របូកច្របល់ និងការពន្យាពេលដំណើរការនីតិវិធីនាកិច្ចចាប់

ផ្ដើមដំបូង ដោយសារតែអ្នកបកប្រែមិនមានសំណុំឯកសារថ្មីនៃសេចក្ដីថ្លែងការណ៍ទាក់ទិននឹងប្រធានបទដែលបានទទួលស្គាល់នោះ យ៉ាងណាមិញ ការនាំយកឯកសារ និងការរត់បំពេញការងាររបស់បុគ្គលិកនៅក្នុងអង្គសវនាក៏បានដោះស្រាយបញ្ហានេះទៅ ។

បន្ទាប់ពីកថាខណ្ឌទីមួយៗបានអានចប់ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ បានសួរទៅកាន់ ឌុច ថា តើ ឌុច មានយោបល់អ្វីបន្ថែម ឬក៏សួរសំណួរមួយ ឬពីរ ដើម្បីបញ្ជាក់ពីព័ត៌មានដែលបានអាននៅក្នុងកថាខណ្ឌទីមួយៗ ។ ទាក់ទិននឹងគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជាក្នុងការ“កម្ទេច”ខ្មាំង ឌុច បានពន្យល់ប្រាប់ថា រាល់សេចក្ដីសម្រេចក្នុងការនាំខ្មាំងមកកាន់មន្ទីរស-២១ គឺធ្វើឡើងដោយសមាជិកគណៈមជ្ឈិម ជាពិសេសគឺ សុន សេន និង នួន ជា ជាបុគ្គលដែល ឌុច ជឿថា បានបំពេញភារកិច្ចជំនួសមុខឲ្យគណៈអចិន្ត្រៃយ៍ ។

ឌុច បានគូសបញ្ជាក់ថា ចាប់តាំងពីឆ្នាំ១៩៧៦ បក្សកុម្មុយនីស្ដកម្ពុជាបានលុបបំបាត់វណ្ណៈកេងប្រវ័ញ្ចមួយភាគធំ ។ ចាប់តាំងពីពេលនោះមក មនុស្សជាច្រើនដែលត្រូវចាប់ខ្លួន និងបញ្ជូនមក មន្ទីរស-២១ គឺជាមនុស្សដែលរស់នៅតាមជនបទ ដែលអ្នកទាំងនោះមានជម្លោះជាមួយនឹងបក្សកុម្មុយនីស្ដកម្ពុជា ។

កាលពីថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៧៦ បក្សកុម្មុយនីស្ដកម្ពុជាបានប្រកាសសិទ្ធិអំណាចរបស់ខ្លួនក្នុងការសម្លាប់ខ្មាំងក្នុងរបបនេះ និងបញ្ជូនខ្មាំងដែលមានតំណែងខ្ពស់នៅក្នុងបដិវត្តន៍ទាំងនោះទៅកាន់មន្ទីរ ស-២១ ។ ការធ្វើបែបនេះគឺជាការចាប់ផ្ដើមនៃរយៈកាលថ្មីមួយដែលការធ្វើវិសុទ្ធកម្មផ្ទៃក្នុងក្លាយជាសកម្មភាពគួរឲ្យកត់សម្គាល់ ។ បក្សកុម្មុយនីស្ដកម្ពុជាបានពង្រីកបញ្ជីឈ្មោះជនទាំងឡាយក្នុងបក្សដែលមានសិទ្ធិអំណាចក្នុងការបញ្ជា និងអនុវត្តការកម្ទេចលើខ្មាំងចំនួនបួនក្រុម ៖ គណៈអចិន្ត្រៃយ៍ភូមិភាគលេខាធិការរបស់គណៈមជ្ឈិម គណៈមជ្ឈិម និងលេខាអគ្គសេនាធិការ ។

ឌុច បានពន្យល់ថា អត្ថន័យនយោបាយនៃពាក្យ“កម្ទេច” មានន័យថា ចាប់ខ្លួន ឃុំឃាំង សួរចម្លើយដោយធ្វើទារុណកម្ម និងសម្លាប់ដោយគ្មានការទទួលដឹងឮពីសមាជិកគ្រួសាររបស់ជនរងគ្រោះ ។ នៅពេលចៅក្រម ហ្សង់ម៉ាក ឡាវែន៍ បន្ទុំឲ្យផ្ដល់នូវន័យដូចនៃពាក្យកម្ទេច ឌុច បាននិយាយថា បើទោះបីជាពាក្យនេះមិនដែលត្រូវបានពន្យល់ប្រាប់ ឌុច ដោយផ្ទាល់ក៏ដោយ ក៏ពាក្យនេះបានផ្ដល់អត្ថន័យថា

បំបែក ឬបំបែកកុំឲ្យមានសល់អ្វីទាំងអស់ ។ ឌុច បានគូសបញ្ជាក់ថា ទាក់ទិននឹងការអនុវត្តពាក្យថា “បំបែក” នេះ មានន័យដូចគ្នានឹងពាក្យកម្ទេចដែរ ។

ឌុច យល់ស្រុបតាមកថាខណ្ឌដែលរៀបរាប់ថា ឌុច បានបង្រៀនមាគ៌ាបក្សនៅមន្ទីរស-២១ រួមទាំងការសម្លាប់ដោយគ្មានការកាត់ក្តី ។ ឌុច បានទទួលស្គាល់បន្ថែមទៀតថា ខ្លួនបានផ្សព្វផ្សាយមាគ៌ាបក្សដោយបង្រៀនអ្នកសួរចម្លើយថា មន្ទីរស-២១ត្រូវតែចូលរួមក្នុងការតស៊ូវណ្ណៈតាមរយៈការកម្ទេចវណ្ណៈជិះជាន់ ។

## ចម្លើយសារភាព

បន្ថែមលើការសម្លាប់អ្នកទោស ឌុច បានយល់ស្របថា គោលបំណងចម្បងមួយទៀតរបស់មន្ទីរស-២១ គឺទាញយកចម្លើយសារភាពដើម្បីស្វែងរកខ្មាំងក្បត់ ។ ឌុច យល់ស្របថា ចម្លើយសារភាពគឺត្រូវបានប្រើប្រាស់ដោយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីកម្ចាត់មនុស្សដែលបង្កជាឧបសគ្គ ដោយមិនចាំបាច់គិតថា តើចម្លើយសារភាពនោះផ្ទុកនូវព័ត៌មានមិនពិតឬយ៉ាងណាឡើយ ។ ឌុច បាននិយាយថា យោងតាមគោលការណ៍ទូទៅ មានតែមនុស្សដែលមានឈ្មោះនៅក្នុងចម្លើយសារភាពតែមួយចំនួនប៉ុណ្ណោះនឹងត្រូវចាប់ខ្លួន ។ ប៉ុន្តែតាមការអនុវត្ត យ៉ាងហោចណាស់សម្រាប់“មនុស្សមិនសូវសំខាន់”មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលត្រូវចាប់ខ្លួន ។ អាស្រ័យលើតួនាទីរបស់ខ្លួនក្នុងការអាន ពិនិត្យ និងបន្ថែមព័ត៌មាននៅក្នុងចម្លើយសារភាពទាំងអស់នោះ ឌុច បាននិយាយថា ខ្លួនមិនមានឧបករណ៍អ្វីដើម្បីថ្លឹងថ្លែងពីភាពត្រឹមត្រូវពិតប្រាកដរបស់ចម្លើយសារភាពទាំងនោះទេ ហើយបញ្ជាក់ទៀតថា ខ្លួនបានព្យាយាមដាក់កម្រិតលើភាពលំអៀងរបស់ខ្លួនទៅកាន់អ្នកទោសទាំងនោះ ។

មានការនិយាយទៅវិញទៅមកជាច្រើនរវាងចៅក្រម ហ្សង់ម៉ាក ឡាវែន៍ និង ឌុច ទាក់ទិននឹងតួនាទីដែល ឌុច បានបំពេញក្នុងការផ្សព្វផ្សាយចម្លើយសារភាពពេញលេញ ឬមានលក្ខណៈលំអៀងទាំងសរសេរដោយដៃ និងថតសម្លេងទុក ។ ឌុច បានពន្យល់ថា ខ្លួនមិនមានសិទ្ធិអំណាចក្នុងការស្នើសុំថាចម្លើយសារភាពត្រូវតែចែកចាយ ឬផ្សព្វផ្សាយនោះទេ ។ ផ្ទុយទៅវិញ ឌុច បាននិយាយថា ខ្លួនបានឃើញចម្លើយសារភាពទាំងនោះនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ ឬទស្សនាវដ្តីយុវជនបដិវត្តន៍ ។ ឌុច បានគូសបញ្ជាក់ថា ចម្លើយសារភាពពេញលេញដែលត្រូវបានផ្សព្វផ្សាយនោះ គឺជាចម្លើយសារភាពរបស់

អ្នកទោសជនជាតិវៀតណាម ។ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ មានចំណាប់អារម្មណ៍យ៉ាងខ្លាំងទាក់ទិននឹងការប្រើប្រាស់ចម្លើយសារភាពជាផ្នែកមួយ នៃការតស៊ូវណ្ណៈផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយ ឌុច បានកត់សម្គាល់ឃើញថា ចម្លើយសារភាពត្រូវបានប្រើប្រាស់នៅក្នុងការតស៊ូអំណាចរវាង ប៉ុល ពត និង តា ម៉ុក ។

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ សួរថាតើ ឌុច បានដឹងថាមានការការពារ ឬតុលាការតាមផ្លូវច្បាប់ណាមួយដែលប្រជាជនអាចការពារសេរីភាពផ្ទាល់ខ្លួនរបស់គេបានដែរឬទេ ប្រសិនបើប្រជាជនទាំងនោះមានឈ្មោះជាប់ពាក់ព័ន្ធនឹងចម្លើយសារភាព ។ ឌុច បានពន្យល់ថា រាល់អំណាចទាំងអស់ដូចជា នីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ ត្រូវបានក្តោបក្តាប់ដោយគណៈមជ្ឈិម ។ ឌុច បាននិយាយថា សេរីភាពរបស់បុគ្គល តុលាការ និងច្បាប់ គឺគ្មានឡើយ គឺមានតែមាគ៌ា និងគោលនយោបាយរបស់បក្សតែប៉ុណ្ណោះ ។

## ការបកប្រែ

ឌុច បានកត់សម្គាល់ពីបញ្ហាបកប្រែ ហើយបានលើកឡើងពីបញ្ហាមួយចំនួននៅក្នុងដំណើរការនីតិវិធីសម្រាប់ថ្ងៃនេះ ។ ឧទាហរណ៍ ឌុច បានប្រៀបធៀបកថាខណ្ឌជាភាសាខ្មែរ និងភាសាបារាំង ហើយបានជម្រុញឲ្យមានភាពស៊ីចង្វាក់គ្នារវាងការបកប្រែលើភាសាទាំងពីរនេះដោយនិយាយថា «ការកត់សម្គាល់» និង«ការបានឃើញដោយភ្នែកផ្ទាល់» មិនបានផ្តល់នូវអត្ថន័យដូចគ្នានោះទេ ។

## សក្ខីកម្មជំនាញពីគោលនយោបាយ និងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា

ដំណើរការនីតិវិធីសម្រាប់ថ្ងៃនេះបានបញ្ចប់ ដោយការធ្វើកសិណសាក្សីជំនាញរបស់លោកបណ្ឌិត ក្រេក អេតឆេសាន់ ជាសាស្ត្រាចារ្យជនជាតិអាមេរិកដែលបានសិក្សាពីកម្ពុជាប្រជាធិបតេយ្យ អស់រយៈពេលប្រមាណ៣០ឆ្នាំ ហើយនាពេលបច្ចុប្បន្ននេះលោកបណ្ឌិតកំពុងតែបំរើការជាអ្នកស៊ើបអង្កេតនៅក្នុងការិយាល័យសហព្រះរាជអាជ្ញានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

លោកស្រីចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ បានសួរ គ្រេក អេតឆេសាន់ ពីសំណួរមួយចំនួនទាក់ទិននឹងអង្គភាពផ្សេងៗរបស់បក្សកុម្មុយនីស្តកម្ពុជា ទំនួលខុសត្រូវរបស់អង្គភាពនីមួយៗ និងឯកសារសំខាន់ៗរបស់បក្សកុម្មុយនីស្តកម្ពុជា មុននឹងឈានចូលដល់ការសួរសំណួររបស់លោកស្រីចៅក្រមលើការអះអាងរបស់ឌុចមួយចំនួន ហើយក៏ទទួលបានការបញ្ជាក់ពីលោកបណ្ឌិតភាគច្រើនៗ គ្រេក អេតឆេសាន់ បានបញ្ជាក់ថា យោងតាមឋានន្តរស័ក្តយ៉ាងម៉ឺងម៉ាត់របស់បក្សកុម្មុយនីស្តកម្ពុជា ឌុច ត្រូវតែតម្រូវឲ្យគោរពតាមបញ្ជារបស់ សុន សេន មានន័យថា គណៈមជ្ឈិមអនុវត្តអំណាចរបស់ខ្លួនទៅលើសន្តិសុខនៅតាមភូមិភាគៗ យ៉ាងណាមិញ លោកមិនយល់ស្របនឹងការអះអាងរបស់ ឌុច ដែលថា សុន សេន បានបញ្ជាឲ្យបង្កើតមន្ទីរស-២១នាឆ្នាំ១៩៧៥ ដោយលោកបានគូសបញ្ជាក់ថា សុន សេន មិនអាចមានសិទ្ធិអំណាចក្នុងការសម្រេចធ្វើដូច្នេះតែម្នាក់ឯងបានទេៗ ជាមួយគ្នានេះ សុន សេន គឺទំនងជាបំពេញកាតព្វកិច្ចរបស់ខ្លួនតាមសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ប៉ុណ្ណោះៗ

លោកបណ្ឌិត គ្រេក អេតឆេសាន់ នឹងវិលត្រឡប់មកឈរជាសាក្សីម្តងទៀតនៅព្រឹកស្អែក ដើម្បីបន្តសក្ខីកម្មរបស់លោកៗ